អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## ពិធីចែកសៀវភៅសាលដីកាស្ថាពរក្នុងសំណុំរឿង ០០១

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងរៀបចំពិធីចែកសៀវភៅសាលដីកាស្ថាពរក្នុងសំណុំរឿង ០០១ ដែលអង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចកាលពីថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ផ្តន្ទាទោសជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដាក់ពន្ធនាគារអស់មួយជីវិត។

ពិធីនេះនឹងប្រព្រឹត្តទៅនៅសាលសវនាការនៃ អ.វ.ត.ក នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១២ ពីម៉ោង ៩:៣០ ព្រឹក ដល់ម៉ោង ១១:០០ ព្រឹក។ សាធារណជនប្រមាណ ៥០០នាក់ ដែលរួមមានតំណាងក្រសួង-មន្ទីរក្នុងរដ្ឋាភិបាល តំណាងសាកលវិទ្យាល័យ និងនិស្សិត នឹងចូលរួមក្នុងពិធីនេះ ក្រោមអធិបតីភាពនិងធ្វើបទឧទ្ទេសនាមដោយឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទីនៃ អ.វ.ត.ក។ ជាមួយគ្នានេះដែរនឹងមានកម្មវិធីសំណួរ-ចម្លើយសម្រាប់អ្នកចូលរួមផងដែរ។

អ្នកសារព័ត៌មានឬតំណាងសារព័ត៌មានដែលមានបំណងចូលរួមយកព័ត៌មានក្នុងកម្មវិធីនេះ សូមនាំមកជាមួយនូវប័ណ្ណព័ត៌មានដែលចេញដោយ អ.វ.ត.ក ឬដោយសាម៉ីស្ថាប័នសារព័ត៌មាន។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៨ ០២៣
សារអេឡិកត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យ អ.វ.ត.ក
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh